សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្ងៃខួបទិវាជាតិអាហារូបត្ថម្ភលើកទី ៥ (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៨)
## ក្រោមប្រធានបទ
## "ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នកគឺជាការវិនិយោគដ៏ប្រសើរបំផុត"

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ជាទីមេត្រី

ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធ **ទិវាជាតិអាហារូបត្ថម្ភលើកទី៥** (៦ វិច្ឆិកា ២០១៤ -៦ វិច្ឆិកា ២០១៨) ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹង ចំពោះការរៀបចំ **ទិវាជាតិអាហារូបត្ថម្ភលើកទី ៥** ក្រោមប្រធានបទ **"ផ្តល់អាហារូបត្ថម្ភល្អដល់កូនអ្នកគឺជាការវិនិយោគដ៏ប្រសើរបំផុត"** ដើម្បីបំផុសស្មារតីដល់ភាគីពាក់ព័ន្ធទាំងអស់ ទាំងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកស្រាវជ្រាវ និងបងប្អូនជនរួមជាតិឱ្យយល់កាន់តែច្បាស់ថា÷ រាល់ការចំណាយទៅលើការផ្តល់អាហារូបត្ថម្ភល្អដល់កុមារ គឺជាការវិនិយោគសម្រាប់ការអភិវឌ្ឍសង្គម មូលធនមនុស្ស និងសេដ្ឋកិច្ចជាតិ និងលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងនោះឱ្យចូលរួមចំណែកដោះស្រាយបញ្ហា អាហារូបត្ថម្ភ ចែករំលែកបទពិសោធន៍ កៀរគរធនធាន និងបង្កើនការវិនិយោគទៅលើអាហារូបត្ថម្ភ ក្នុងគោលដៅដើម្បីកុមារ និងស្ត្រីមានសុខភាពល្អ ប្រសិទ្ធភាពការងារ និងដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍសង្គមជាតិយើង។ ផ្អែកតាមការសិក្សាបែបវិទ្យាសាស្ត្របានបង្ហាញថារាល់ការវិនិយោគចំនួនមួយ (០១) ដុល្លារ លើអាហារូបត្ថម្ភ យើងនឹងបានទទួលផលដោយប្រយោលចំនួន១៦ដុល្លារ មកវិញតាមរយៈការបង្កើនមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចជាតិសម្រាប់ថ្ងៃអនាគត។

ខ្ញុំព្រះករុណា ខ្ញុំ សូមឆ្លៀតឱកាសនេះជម្រាបជូនជនរួមជាតិជ្រាបថា÷ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពសង្គមគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រីក្នុងវ័យបន្តពូជ មាតា ទារក និងកុមារ។ ផ្អែកតាមលទ្ធផលអង្កេតសុខភាពប្រជាសាស្ត្រ

ឆ្នាំ២០១៤ របស់ក្រសួងផែនការ បានបង្ហាញថាអត្រាកុមារក្រិសក្រិនត្រូវបានកាត់បន្ថយពីចំនួន ៥០% នៅឆ្នាំ២០០០ មកត្រឹម ៣២% នៅឆ្នាំ២០១៤ អត្រាកុមារមានទម្ងន់ទាបត្រូវបានកាត់បន្ថយពីចំនួន ៣៩% នៅឆ្នាំ២០០០ មកត្រឹម ២៤% នៅឆ្នាំ២០១៤ អត្រាស្ត្រីក្នុងវ័យបន្តពូជកង្វះអាហារូបត្ថម្ភត្រូវបានកាត់បន្ថយពីចំនួន ២១% នៅឆ្នាំ២០០០ មកត្រឹម ១៤% នៅឆ្នាំ២០១៤ និងអត្រានៃការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ និងការបំបៅកូនដោយទឹកដោះម្ដាយក្នុងម៉ោងដំបូងក្រោយសម្រាល មានការកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០០ ដល់២០១០។ ទន្ទឹមនេះ ការលើកកម្ពស់អាហារូបត្ថម្ភត្រូវបានរាជរដ្ឋាភិបាលផ្ដល់អាទិភាពខ្ពស់ក្នុងគោលនយោបាយលើកកម្ពស់មូលធនមនុស្ស និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ផ្អែកតាមទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលបានបង្ហាញថា សមាមាត្រប្រជាជនកម្ពុជាដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រមានចំនួន ១៣,៥% ហើយការកាត់បន្ថយអត្រានៃភាពក្រីក្រនេះ នឹងត្រូវសម្រេចឱ្យបានលើស១% ក្នុងមួយឆ្នាំ ដែលនេះ ទាមទារឱ្យមានវឌ្ឍនភាពពីគ្រប់វិស័យ ដើម្បីជំរុញទស្សនវិស័យរបស់រាជរដ្ឋាភិបាលទទួលបានជោគជ័យ។

**ជនរួមជាតិទាំងអស់ជាទីស្នេហា !**

ទោះបីជាបញ្ហាក្រិសក្រិនរបស់កុមារថយចុះមកនៅត្រឹម ៣២%ក៏ដោយ ក៏អត្រានេះនៅតែមានកម្រិតខ្ពស់នៅឡើយ។ អត្រាក្រិសក្រិនខ្ពស់នេះ គឺជាការគម្រាមកំហែងមួយ និងរាំងស្ទះដល់និរន្តរភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ធនធានមនុស្ស និងការរីកចម្រើនរបស់ប្រទេសជាតិផងដែរ។ កង្វះអាហារូបត្ថម្ភបានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានលើការសិក្សារបស់កុមារ ក៏ដូចជាប្រសិទ្ធភាពការងាររបស់ពួកគេនៅពេលដែលពួកគេធំឡើង និងបង្កជាហេតុធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិ។ ការដោះស្រាយបញ្ហាក្រិសក្រិនមានសារៈសំខាន់ណាស់ និងចាំបាច់ដើម្បីឱ្យកម្ពុជាអាចសម្រេចគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ២០៣០។ កង្វះអាហារូបត្ថម្ភបានធ្វើឱ្យប៉ះពាល់ដល់ការខាតបង់ខាងសេដ្ឋកិច្ចដ៏ធំធេង ដែលបង្កដោយកត្តាសក្ដានុពលមួយចំនួន ដូចជាប្រជាពលរដ្ឋភាគច្រើននៅតាមតំបន់ជនបទទទួលបានអាហារសម្បូរសារជាតិចិញ្ចឹមនៅមានកម្រិតទាប អត្រាជំងឺឆ្លងមានកម្រិតខ្ពស់ ការប្រើប្រាស់ទឹកស្អាតនិងអនាម័យនៅពុំទាន់បានល្អ និងទម្លាប់ការបរិភោគអាហាររបស់មាតា និងការចិញ្ចឹមទារក និងកុមារតូច នៅពុំទាន់បានសមស្របនៅឡើយ ការយល់ដឹងពីអនាម័យនិងសុវត្ថិភាពចំណីអាហារនៅមានកម្រិត ហើយអត្រាមរណភាពនិងកង្វះអាហារូបត្ថម្ភរបស់មាតាទារក និងកុមារក្នុងចំណោមគ្រួសារក្រីក្រនៅជនបទនៅតែជាបញ្ហាប្រឈមនៅឡើយ។

ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពចម្បងទៅលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងចាត់ទុកការវិនិយោគលើអាហារូបត្ថម្ភគឺជា "កម្លាំងពន្លឿន" ក្នុងការជួយបង្កើនល្បឿនដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពដទៃទៀត ដែលទាក់ទងនឹងសុខុមាលភាពរបស់ប្រជាជន ជួយអភិវឌ្ឍមូលធនមនុស្ស និងសេដ្ឋកិច្ចជាតិ ហើយរាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តដោយមិន

ទុកឱ្យប្រជាជនណាម្នាក់ស្ថិតក្នុងភាពអត់ឃ្លាន និងក្រីក្រឡើយ។ ក្នុងន័យនេះ ការសម្របសម្រួល និងកិច្ចអន្តរាគមន៍អន្តរវិស័យ និងការវិនិយោគនៅក្នុងវិស័យកសិកម្ម សុខាភិបាល អប់រំ ទឹកស្អាតនិងអនាម័យ យេនឌ័រ កិច្ចគាំពារសង្គម និងជំនួយសង្គម និងវិស័យពាក់ព័ន្ធផ្សេងៗទៀត រួមនឹងការបង្កើនកញ្ចប់ថវិកាជាតិជារៀងរាល់ឆ្នាំទៅឱ្យក្រសួងជំនាញទាំងនោះដើម្បីប្រើប្រាស់ និងអនុវត្តផែនការសកម្មភាពតាមវិស័យរបស់ខ្លួន គឺជាការងារអាទិភាព ដើម្បីលុបបំបាត់ **បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ទាំងអស់** នៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៤ (២០១៨ -២០២៣) បានបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួន ក្នុងការលើកស្ទួយសុខុមាលភាពរបស់ប្រជាជនតាមរយៈការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម ជាពិសេសក្នុងចំណោមជនក្រីក្រ និងជនងាយរងគ្រោះ។

ក្នុងឱកាសប្រារព្ធទិវាជាតិអាហារូបត្ថម្ភលើកទី ៩ នាឆ្នាំនេះ និងក្នុងគោលបំណងអនុវត្តសកម្មភាពលុបបំបាត់បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ទាំងអស់ឱ្យមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធខ្ពស់ថែមទៀត រាជរដ្ឋាភិបាលសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោមនេះ÷

**ទី១-** បន្តពង្រឹងភាពជាដៃគូ និងបន្តខិតខំសម្របសម្រួល សហការគ្នា ដើម្បីធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភស្ត្រី និងកុមារ មានភាពល្អប្រសើរឡើង តាមរយៈការអប់រំផ្សព្វផ្សាយស្តីពីការបរិភោគអាហារចម្រុះ សម្បូរប្រូតេអ៊ីន អាហារតាមពេល និងមានសុវត្ថិភាព និងអាហារមានមីក្រូសារជាតិគ្រប់គ្រាន់ ពិសេសត្រូវហូបត្រី ឬក៏អាហារធ្វើពីម្សៅត្រីដែលជាប្រភពមានអាហារូបត្ថម្ភច្រើនសម្រាប់ការលូតលាស់ និងការវិវឌ្ឍរបស់កុមារ។

**ទី២-** បន្តវិនិយោគលើការពង្រឹងពិពិធកម្មស្បៀងអាហារ តាមរយៈការលើកកម្ពស់ផលិតកម្មស្បៀងតាមគ្រួសារ អនាម័យនិងទឹកស្អាត ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ និងការពង្រឹងភាពម្ចាស់ការរបស់ស្ត្រីក្នុងការដោះស្រាយអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្តោតលើការធ្វើពិពិធកម្មដំណាំ និងគ្រាប់ពូជដំណាំ ដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ សម្បូរអាហារូបត្ថម្ភ និងបង្កើនផលិតកម្មបន្លែ ផ្លែឈើ បក្សី និងត្រី-សាច់ ប្រព័ន្ធស្បៀងអាហារនិងការផ្លាស់ប្តូរឥរិយាបថ ដើម្បីលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សុវត្ថិភាពស្បៀង និងលើកកម្ពស់គុណភាពស្បៀងសម្រាប់ជនរួមជាតិយើង។

**ទី៣-** បន្តអន្តរាគមន៍អាហារូបត្ថម្ភក្នុងបរិបទវិស័យសុខាភិបាល រួមមានការផ្តល់ប្រឹក្សាយោបល់ស្តីពីអាហារូបត្ថម្ភក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយសម្រាល និងរក្សានិរន្តរភាពទម្លាប់ការបំបៅកូនដោយ ទឹកដោះម្តាយឱ្យបានល្អបំផុតសម្រាប់កុមារកម្ពុជា រួមមានការចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយក្នុងម៉ោងដំបូងក្រោយពីសម្រាល ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងអំឡុង៦ខែដំបូង និងការបន្តបំបៅកូនដោយទឹកដោះម្តាយឱ្យបានរហូតដល់កុមារអាយុយ៉ាងតិចបំផុត ២ ឆ្នាំឬលើស។

**ទី៤-** បន្តជំរុញ និងធានាឱ្យទារកនិងកុមារតូចអាយុ ៦-២៤ ខែ ទទួលបានអាហារបន្ថែមសមស្រប តាមរយៈការផ្តល់ឱ្យទារកនិងកុមារនូវអាហារចម្រុះក្នុងបរិមាណសមស្រប តាមអាយុប្រកបដោយសុវត្ថិភាព និង

ងាយស្រួលរកបាន ជាពិសេសអាហារដែលមានប្រភពពីសត្វ និងអាហារបំប៉នបន្ថែមដែលនាំមកនូវ សុខភាពល្អ។

**ទី៥-** បន្តអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់ឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ នៃគ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗ រួមនឹងយន្តការសម្របសម្រួលពហុវិស័យ កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន ដោយមានការចូលរួមពីសហគមន៍ វិស័យឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់អាហារូបត្ថម្ភនៅតាមសហគមន៍ និងសាលារៀន។

**ទី៦-** បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងផ្សារភ្ជាប់ការលើកកម្ពស់អាហារូបត្ថម្ភ និងក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដល់ប្រជាជន ដើម្បីសម្រេចឱ្យបានចក្ខុវិស័យរបស់វិស័យនេះដែលបានចែងថា នៅមុនបំណាច់ឆ្នាំ២០២៥ ប្រជាជនគ្រប់រូបនៅតាមសហគមន៍ជនបទ មានលទ្ធភាពទទួលបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ប្រកបដោយសុវត្ថិភាព និងរស់នៅក្នុងបរិស្ថានមានអនាម័យ។

**ទី៧-** បន្តវិនិយោគទៅលើរបកគំហើញ និងបច្ចេកវិទ្យាថ្មីៗ និងពង្រឹងការស្រាវជ្រាវ ប្រមូល វិភាគ ចងក្រង ផ្សព្វផ្សាយទិន្នន័យ និងប្រើប្រាស់ទិន្នន័យស្តីពីការដាំដុះ និងទីផ្សារផលិតផលកសិកម្ម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ឱ្យកាន់តែល្អប្រសើរឡើង ទៅដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំផែនការ និងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ដែលជួយឱ្យយើងអាចពិនិត្យតាមដានពីវឌ្ឍនភាពដោយមានប្រសិទ្ធភាព និងក្នុងការកំណត់ពីអភិក្រមនៃការអនុវត្តសមស្រប។

**ទី៨-** បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦ -២០២៥ តាមរយៈការអនុវត្តកម្មវិធីជាតិជំនួយសង្គមថ្មីៗ និងពង្រីកកម្មវិធីដែលមានស្រាប់និងរៀបចំនិងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ២០១៩ -២០២៣ សំដៅបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងជនងាយរងគ្រោះ ដែលជួបប្រទះបញ្ហាអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងបងប្អូនជនរួមជាតិទាំងអស់ ចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជាសេនាធិការក្នុងការសម្របសម្រួលលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដោយរួមគ្នាបន្តខិតខំប្រឹងប្រែងការអន្តរាគមន៍ និងការវិនិយោគបន្ថែម ដើម្បីលុបបំបាត់ **បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ទាំងអស់** និងសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០ គឺ មិនទុកឱ្យនរណាម្នាក់មានបញ្ហាកង្វះស្បៀង និងរងគ្រោះពីបញ្ហាអាហារូបត្ថម្ភ" និងគោលដៅទី២ នៃគោលដៅអភិវឌ្ឍដោយចីរភាពគឺ " **បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង លើកកម្ពស់ស្ថានភាព អាហារូបត្ថម្ភ និងកសិកម្មប្រកបដោយចីរភាព**"។

ជាចុងបញ្ចប់ ក្នុងឱកាសការប្រារព្ធ **ទិវាជាតិអាហារូបត្ថម្ភលើកទី ៥** (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៨) ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរដល់សម្តេចព្រះសង្ឃរាជទាំង

ពិរតណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់សូមប្រកបទៅដោយពុទ្ធពរទាំង ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០១៨

**ហ៊ុន សែន**